# សុន្ទរកថារបស់លោកអ៊ីហ្សាវ៉ា កាស៊ឹហ៊ីរ៉ូ
# លេខាទីពីរ ស្ថានទូតជប៉ុន
# ថ្លែងក្នុងពិធីសម្ពោធអាងស្តុកទឹកចំនួន១៦ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង
# ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣

**សូមគោរព ឯកឧត្តម អ៊ុយ រី អភិបាលរងខេត្តបាត់ដំបង!**
**សូមគោរព ឯកឧត្តម ទ្រឿង មាលី ទីប្រឹក្សាអង្គការស្តាបនាកម្ពុជា និងជាទីប្រឹក្សាជាន់ខ្ពស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា!**
**សូមគោរព លោក គុជ រូសាល នាយកប្រតិបត្តិអង្គការស្តាបនាកម្ពុជា!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយខ្លាំងណាស់ ដោយបានចូលរួមក្នុងពិធី សម្ពោធអាងស្តុកទឹកចំនួន ១៦ក្នុងស្រុកសង្កែ ខេត្តបាត់ដំបងជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ទ្រឿង មាលី ទីប្រឹក្សាអង្គការស្តាបនាកម្ពុជា និងជាទីប្រឹក្សាជាន់ខ្ពស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។ ជាបឋម ខ្ញុំសូមសំដែងនូវការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការស្តាបនាកម្ពុជា និងប្រជាជនក្នុងតំបន់ដែលបានរៀបចំឲ្យមានកម្មវិធីនេះឡើង។

ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយជាពិសេសដែលពិធីនេះត្រូវបានប្រារព្ធឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣ ដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

ការផ្គត់ផ្គង់ទឹកស្អាត គឺជាអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់ជប៉ុនសម្រាប់កម្ពុជាហើយជាក់ស្តែងគម្រោងផ្នែកទឹកស្អាតជាច្រើនត្រូវបានអនុវត្តទាំងនៅទីក្រុង ទាំងនៅតំបន់ជនបទ។ ក្នុងន័យនេះ គម្រោងសាងសង់អាងស្តុកទឹកចំនួន១៦ក្នុងស្រុកសង្កែ ខេត្តបាត់ដំបងទើបតែត្រូវបានអនុវត្តថ្មីៗនេះ។

ខ្ញុំបានទទួលដំណឹងថាការសាងសង់អាងស្តុកទឹកក្នុងសាលាបឋមសិក្សាទាំង១៦នេះ ផ្តល់អត្ថប្រយោជន៍ដល់សិស្សានុសិស្ស៨,៤៦៤នាក់ និងលោកគ្រូ-អ្នកគ្រូ៣២៤នាក់ ក្នុងស្រុកសង្កែដើម្បីទទួលបានទឹកស្អាតប្រើប្រាស់។ ខ្ញុំក៏បានទទួលដំណឹងផងដែរថា គណៈកម្មការថែទាំអាងស្តុកទឹកទាំងនេះ ត្រូវបានបង្កើតឡើងនៅតាមសាលានិមួយៗដោយមានការគាំទ្រពីអង្គការស្តាបនាកម្ពុជា។ ខ្ញុំសង្ឃឹមថាគណៈកម្មការទាំងអស់នឹងថែទាំអាងស្តុកទឹកទាំងនេះឲ្យបានត្រឹមត្រូវដើម្បីអ្នកប្រើប្រាស់ទាំងអស់អាចប្រើប្រាស់បានប្រកបដោយអនាម័យ។

ជាចុងក្រោយ ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅបានយ៉ាងរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាអាងស្តុកទឹកទាំងនេះនឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ ព្រមទាំងជួយពង្រឹងជាបន្តនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!